ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧៤ អនក្រ.បក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ ៣៤៨៤/១៨
ថ្ងៃទី ២-១១-១៨
បញ្ជូន.........

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនាយកដ្ឋាន

ផែនការនិងស្ថិតិនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

ត្រូវបានដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ ..**

អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វមានតួនាទីជាសេនាធិការឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើការងារសុខភាពសត្វនិងផលិតកម្មសត្វ និងមានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង អភិវឌ្ឍ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃអនាម័យ សុខុមាលភាព ទាក់ទងនឹងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ជំរុញការចិញ្ចឹមសត្វនិងធានានិរន្តរភាពនៃការផ្គត់ផ្គង់សត្វនិងផលិតផលសត្វប្រកបដោយគុណភាព និងសុវត្ថិភាព តាមរយៈការរៀបចំនិងការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រ លើកកម្ពស់ការស្រាវជ្រាវ បណ្តុះបណ្តាល និងការអភិវឌ្ឍ លើការបង្កាត់ពូជសត្វ ប្រព័ន្ធកសិដ្ឋាន ការគ្រប់គ្រងចំណីសត្វ បសុឱសថ និងសេវាកម្មសុខភាពសត្វ
- រួមចំណែកបង្កើនចំណូលដល់សេដ្ឋកិច្ចជាតិនិងកសិករ តាមរយៈការលើកទឹកចិត្តការវិនិយោគ ការសម្រួលពាណិជ្ជកម្ម ពាក់ព័ន្ធវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិ លើវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- រៀបចំផែនការអភិវឌ្ឍស្តីពីការគ្រប់គ្រងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ ដែលបង្ហាញពីគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍវិស័យសុខភាពសត្វនិងផលិតកម្មសត្វដោយមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់
- រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា សំដៅគ្រប់គ្រងវិស័យសុខភាពសត្វនិងផលិតកម្មសត្វឱ្យមានប្រសិទ្ធភាព

- ជំរុញ គ្រប់គ្រង និងលើកកម្ពស់ផលិតកម្មសត្វ តាមរយៈការបង្កើនផលិតភាព ការលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច ការធានាសុខុមាលភាពសត្វ និងការបង្ការហានិភ័យសុខភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន
- គ្រប់គ្រងនិងត្រួតពិនិត្យអនាម័យ ប្រសិទ្ធភាពនិងសុវត្ថិភាពចំណីសត្វ វត្ថុធាតុដើម សារធាតុបន្ថែមសម្រាប់លាយផ្សំចំណីសត្វ និងបសុឱសថ
- គ្រប់គ្រងនិងត្រួតពិនិត្យអនាម័យសត្វ សាច់ ផលិតផលសត្វ អាជីវកម្មពិឃាតសត្វ សត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វនិងកន្លែងបង្កាត់ពូជសត្វ ស្ថានីយចត្តាឡីស័កសត្វ ទីកន្លែង ព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ ព្រមទាំងកន្លែងផ្សេងទៀត
- ត្រួតពិនិត្យអនាម័យ វិញ្ញាបនបត្រ ចរាចរណ៍សត្វ និងផលិតផលសត្វ ស្របតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល
- ត្រួតពិនិត្យអនាម័យកន្លែងតាំងលក់សត្វ សាច់ ផលិតផលសត្វដោយសហការជាមួយក្រសួងពាក់ព័ន្ធ
- អង្កេត តាមដាន ស្រាវជ្រាវជំងឺសត្វ ជំងឺស៊ូណូស ការចិញ្ចឹមសត្វ ជ្រើសរើសពូជ និងធ្វើរោគវិនិច្ឆ័យជំងឺសត្វ វាយតម្លៃគុណភាពសុវត្ថិភាពចំណីសត្វនិងបសុឱសថ
- រៀបចំផលិតឯកសារផ្សព្វផ្សាយព័ត៌មាន អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រាស្រ័យទាក់ទងបច្ចេកទេសស្ថានភាពផលិតកម្មនិងតម្រូវការទីផ្សារ លិខិតបទដ្ឋាន កម្មវិធីអភិវឌ្ឍ និងព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យសុខភាពសត្វនិងផលិតកម្មសត្វដល់អ្នកចិញ្ចឹមសត្វ ផ្នែកឯកជន ពាណិជ្ជករ អាជីវករ និងអ្នកពាក់ព័ន្ធវិស័យសុខភាពសត្វនិងផលិតកម្មសត្វ ដើម្បីបង្កើនផលិតភាពគុណភាព ប្រសិទ្ធភាពផលិតកម្មសត្វ ផលិតផលសត្វ និងការធ្វើពាណិជ្ជកម្ម
- ធ្វើសហប្រតិបត្តិការជាមួយអង្គភាពនិងស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន ដៃគូអភិវឌ្ឍ សហគមន៍ សមាគម អង្គការជាតិ និងអង្គការអន្តរជាតិនានាទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ធ្វើអធិការកិច្ចលើរាល់សកម្មភាពពាក់ព័ន្ធវិស័យសុខភាពសត្វនិងផលិតកម្មសត្វ និងជំរុញការអនុវត្តច្បាប់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ជូន។

អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ដឹកនាំដោយអគ្គនាយក១រូប និងអគ្គនាយករងមួយចំនួនស្របតាមអនុក្រឹត្យលេខ១១៤អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**មាត្រា៣ .-**

រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ មាននាយកដ្ឋានចំនួន៤ និងវិទ្យាស្ថានចំនួន១ ដូចខាងក្រោមៈ

- នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ
- នាយកដ្ឋានផលិតកម្មសត្វ
- នាយកដ្ឋានសុខភាពសត្វនិងសុខភាពសាធារណៈបសុព្យាបាល

- នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្ម
- វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វនិងផលិតកម្មសត្វ

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាននាយកដ្ឋាន១រូប និងអនុប្រធាននាយកដ្ឋានមួយចំនួនស្រប តាមអនុក្រឹត្យលេខ១១៤អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិង មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ដឹកនាំដោយនាយក១រូប ឋានៈស្មើប្រធាន នាយកដ្ឋាន និងនាយករងមួយចំនួន ឋានៈស្មើអនុប្រធាននាយកដ្ឋាន ស្របតាមអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធ គ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

អង្គការលេខរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ ..**

នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកា និងការងារទូទៅរបស់នាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ដោយរាប់ទាំងការគ្រប់គ្រង ស្ថិតិមន្ត្រី ចូលរួមត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ លើកសំណើតែងតាំង ផ្ទេរភារកិច្ច លើក សរសើរឬដាក់ពិន័យ រៀបចំគោលនយោបាយពាក់ព័ន្ធនឹងក្របខណ្ឌបៀវត្ស ប្រាក់កម្រៃ និងរបបឧបត្ថម្ភ ផ្សេងៗ
- គ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅ សណ្ដាប់ធ្នាប់ សន្តិសុខ ពិធីការ ក្នុងអគ្គនាយកដ្ឋានសុខភាពសត្វនិង ផលិតកម្មសត្វ
- សម្របសម្រួលនិងទំនាក់ទំនងការងាររដ្ឋបាល ការងារសាធារណៈ ផ្លាស់ប្ដូរព័ត៌មាន ការងារសហ-ប្រតិបត្តិការជាមួយអង្គភាព ស្ថាប័ន ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិ ភ្នាក់ងារ និងបណ្ដា ប្រទេសនានា
- រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងបណ្ដុះបណ្ដាលដល់មន្ត្រីអគ្គនាយកដ្ឋានសុខភាពសត្វនិង ផលិតកម្មសត្វ និងអ្នកពាក់ព័ន្ធលើការងារផែនការ គណនេយ្យ និងហិរញ្ញវត្ថុ ការលើកថវិកាតាមកម្មវិធី អនុកម្មវិធី និងគម្រោង នីតិវិធីចំណាយនិងការទូទាត់ និងជំរុញលើកទឹកចិត្តឱ្យមានសមត្ថភាពនិង សមធម៌យេនឌ័រ
- គ្រប់គ្រងការទទួល ការបញ្ជូន និងបែងចែកលិខិត ការចេញលិខិតឧទ្ទេសនាម លិខិតបញ្ជាបេសកកម្ម
- រៀបចំធ្វើរបាយការណ៍ការងារនិងសកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្ម សត្វ
- ជំរុញ សម្របសម្រួលរៀបចំគោលនយោបាយជាតិ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍវិស័យសុខភាព សត្វនិង ផលិតកម្មសត្វ ផែនការថវិកាកម្មវិធីនិងអនុកម្មវិធី និងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាន សុខភាព សត្វនិងផលិតកម្មសត្វ

- ប្រមូលទិន្នន័យ ព័ត៌មាន ស្ថិតិ និងវិភាគលើវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ទទួលខុសត្រូវលើការងាររៀបចំនិងតាមដានការអនុវត្តថវិកា
- ទទួលខុសត្រូវគ្រប់គ្រងពាក់ព័ន្ធការងារគណនេយ្យនិងហិរញ្ញវត្ថុ ការងារលទ្ធកម្មសាធារណៈ ការទទួលរក្សានិងគ្រប់គ្រងឧបករណ៍ សម្ភារៈ បរិក្ខារ ទ្រព្យសម្បត្តិផ្សេងៗ គ្រប់គ្រងអចលនទ្រព្យនិងធ្វើបញ្ជីសារពើភណ្ឌរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- វិភាគ ផ្តល់យោបល់ និងរៀបចំគម្រោងវិនិយោគសាធារណៈនិងវិនិយោគឯកជនក្នុងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- គ្រប់គ្រងការប្រមូលចំណូលនិងចំណាយគ្រប់ប្រភេទរបស់អគ្គនាយកដ្ឋានត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រងការងារសហប្រតិបត្តិការអន្តរជាតិ ទំនាក់ទំនងសម្របសម្រួលរៀបចំគម្រោងកិច្ចសហប្រតិបត្តិ-ការអន្តរជាតិជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា
- តាមដាន ជំរុញ និងវាយតម្លៃការអនុវត្តគម្រោងថវិកាតាមកម្មវិធី អនុកម្មវិធីនិងគម្រោងសហប្រតិបត្តិការ រៀបចំកំណត់ហេតុកិច្ចប្រជុំ រៀបចំអនុស្សរណៈយោគយល់គ្នា ពិធីសារ អនុសញ្ញា និងកិច្ចព្រមព្រៀងនានាទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- រៀបចំកិច្ចប្រជុំ សិក្ខាសាលានិងផ្សព្វផ្សាយដល់អង្គភាពសុខភាពសត្វនិងផលិតកម្មសត្វ វិស័យឯកជន អង្គការជាតិនិងអង្គការអន្តរជាតិ ភ្នាក់ងារផ្តល់ជំនួយផ្សេងៗ អ្នកពាក់ព័ន្ធផ្សេងៗ អំពីគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រា៥ ..**

នាយកដ្ឋានផលិតកម្មសត្វ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកា និងការងារទូទៅរបស់នាយកដ្ឋាន
- រៀបចំផែនការផលិតកម្មសត្វឱ្យស្របតាមគោលនយោបាយនិងទីផ្សារតម្រូវ សិក្សាស្រាវជ្រាវពី សក្តានុពល សេចក្តីត្រូវការ ការផ្គត់ផ្គង់សត្វនិងផលិតផលសត្វ
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន វាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមនិងបំប៉នសត្វ ទីកន្លែងបង្កាត់ពូជសត្វ
- ត្រួតពិនិត្យ តាមដាន វាយតម្លៃទីកន្លែងផលិតនិងលាយផ្សំចំណីសត្វ
- គ្រប់គ្រង អភិរក្ស អភិវឌ្ឍធនធានសេនេទិចសត្វ និងធ្វើបញ្ជីពូជសត្វ
- ប្រមូល វិភាគចងក្រងទិន្នន័យ ជំរឿន ស្រង់ស្ថិតិសត្វគ្រប់ប្រភេទ ស្ថិតិកសិដ្ឋានចិញ្ចឹមសត្វ ស្ថិតិកន្លែងបង្កាត់ពូជសត្វ ស្ថិតិកន្លែងផលិត លាយផ្សំចំណីសត្វ កន្លែងលក់ចំណីសត្វ និងមន្ទីរពិសោធន៍វិភាគចំណីសត្វ
- រៀបចំធ្វើអត្តសញ្ញាណកម្មសត្វ ប្រព័ន្ធតាមដានសត្វនិងផលិតផលសត្វ

- គ្រប់គ្រងកាកសំណល់សត្វ គ្រប់គ្រងការងារឡជីវឧស្ម័ន តាមដាននិងវាយតម្លៃផលប៉ះពាល់បណ្តាលពីផលិតកម្មសត្វ
- គ្រប់គ្រងផលិតកម្មចំណីសត្វ អនុវត្តបង្ហាញនិងផ្សព្វផ្សាយចំណីសត្វ បច្ចេកទេសផ្សំចំណីសត្វ រៀបចំបមាណីយចំណីសត្វ និងត្រួតពិនិត្យគុណភាព ការវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានចំណីសត្វ វត្ថុធាតុដើមសម្រាប់លាយផ្សំចំណីសត្វ និងសារធាតុបន្ថែមសម្រាប់លាយផ្សំចំណីសត្វ
- តាមដាននិងវិភាគទិន្នន័យតម្លៃសត្វ សាច់ ផលិតផលសត្វ ចំណីសត្វ វត្ថុធាតុដើមសម្រាប់ចំណីសត្វ និងសារធាតុបន្ថែមសម្រាប់ចំណីសត្វ ព្រមទាំងសម្ភារៈបម្រើការចិញ្ចឹមសត្វ
- ចូលរួមពិសោធស្រាវជ្រាវនិងផ្សព្វផ្សាយលើការចិញ្ចឹមសត្វ ការបង្កាត់ពូជសត្វតាមបច្ចេកវិទ្យាទំនើប ការធ្វើបង្ហាញលើការចិញ្ចឹមសត្វ បច្ចេកទេសផលិត លាយផ្សំចំណីសត្វនិងដំណាំចំណីសត្វ
- បណ្តុះបណ្តាលបច្ចេកទេសផលិតកម្មសត្វដល់អ្នកពាក់ព័ន្ធ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រា៦ .-**

នាយកដ្ឋានសុខភាពសត្វនិងសុខភាពសាធារណៈបសុព្យាបាល មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖
- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកា និងការងារទូទៅរបស់នាយកដ្ឋាន
- រៀបចំផែនការយុទ្ធសាស្រ្តស្តីពីសុខភាពសត្វនិងជំងឺស៊ូណូស
- ត្រួតពិនិត្យអនាម័យសត្វ ផលិតផលសត្វ បសុឱសថ និងចំណីសត្វ
- គ្រប់គ្រងសត្តឃាតដ្ឋាន អាជីវកម្មពិឃាតសត្វ ត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន និងត្រួតពិនិត្យអនាម័យសត្វ សាច់ ផលិតផលសត្វនៅសត្តឃាតដ្ឋាននិងទីកន្លែងតាំងលក់
- គ្រប់គ្រង ពង្រឹង សម្របសម្រួលនិងធ្វើឱ្យប្រសើរឡើងនូវសេវាកម្មបសុព្យាបាលនិងសេវាសុខភាពសាធារណៈបសុព្យាបាល
- ត្រួតពិនិត្យ តាមដាន រាយការណ៍ស្ថានភាពសុខភាពសត្វ ស្ថានភាពជំងឺស៊ូណូស និងចាត់វិធានការបសុព្យាបាលដើម្បីបង្ការ ទប់ស្កាត់ ករណីមានផ្ទុះជំងឺឆ្លងរាលដាលនិងកំណត់ផែនទីតំបន់ផ្ទុះជំងឺឆ្លងសត្វ និងជំងឺស៊ូណូស
- តាមដាន ពិនិត្យ ជំរុញការចាក់ថ្នាំការពារជំងឺឆ្លងសត្វ និងអន្តរាគមន៍ចាក់ថ្នាំការពារ ពិនិត្យនិងព្យាបាលជំងឺសត្វ
- ត្រួតពិនិត្យ តាមដាន វាយតម្លៃអនាម័យសត្វនិងផលិតផលសត្វ នៅទីកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងបង្កាត់ពូជសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ស្ថានីយចត្តាឡីស័កសត្វនិងផលិតផលសត្វ ទីកន្លែងកែច្នៃផលិតផលសត្វ ទីកន្លែងអាជីវកម្មសត្វ មន្ទីរព្យាបាលសត្វ ទីកន្លែងព្យាបាលសត្វ
- គ្រប់គ្រង ត្រួតពិនិត្យគុណភាព ប្រសិទ្ធភាព សុវត្ថិភាព ការធ្វើពាណិជ្ជកម្ម អាជីវកម្មលក់ដូរ និងការតាំងលក់បសុឱសថ ការផលិត លាយផ្សំ ការប្រើប្រាស់បសុឱសថ សម្ភារៈបរិក្ខារបសុព្យាបាល
- គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃទីកន្លែងពិនិត្យព្យាបាលសត្វនិងមន្ទីរព្យាបាលសត្វ

- រៀបចំបទដ្ឋានគតិយុត្ត សេចក្តីណែនាំ គោលការណ៍ណែនាំ បទបញ្ជា អនុសាសន៍ទាក់ទងសុខភាពសត្វ ជំងឺសត្វ ជំងឺស៊ូណូស វិធានការបសុព្យាបាលនិងវិធានការការពារជំងឺសត្វ និងជំងឺស៊ូណូស
- រៀបចំប្រកាសស្តីពីតំបន់ផ្ទុះជំងឺឆ្លងសត្វ តំបន់ផ្ទុះជំងឺស៊ូណូស និងកំណត់ផែនទីតំបន់ផ្ទុះជំងឺទាំងនេះ
- រៀបចំបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ ជំរុញសកម្មភាពអប់រំនិងផ្សព្វផ្សាយស្តីពីការបង្ការនិងទប់ស្កាត់អំពើទារុណកម្មលើសត្វ និងគ្រប់គ្រង ត្រួតពិនិត្យ តាមដាននិងវាយតម្លៃការអនុវត្តបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ
- រៀបចំបទដ្ឋានគតិយុត្ត សេចក្តីណែនាំ គោលការណ៍ណែនាំ បទបញ្ជា អនុសាសន៍ទាក់ទងបច្ចេកទេស និងការរៀបចំចងក្រងឯកសារស្តីពីនីតិវិធី បែបបទសម្រាប់ការនាំចេញ ការនាំចូល ការនាំឆ្លងកាត់ចរាចរក្នុងផ្ទៃប្រទេសនូវសត្វ ផលិតផលសត្វ ចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមផ្សំចំណីសត្វ បសុឱសថនិងសារធាតុសកម្មសម្រាប់ផលិតបសុឱសថ
- សហការរៀបចំ បណ្តុះបណ្តាល ត្រួតពិនិត្យវាយតម្លៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលនិងភ្នាក់ងារសុខភាពសត្វភូមិ និងចុះបញ្ជី គ្រប់គ្រងនិងធ្វើបច្ចុប្បន្នកម្មគ្រូបង្គោលនិងភ្នាក់ងារសុខភាពសត្វភូមិ
- សហការរៀបចំ ចងក្រងឯកសារបច្ចេកទេសស្តីពីជំងឺសត្វ ជំងឺស៊ូណូស វិធានការការពារនិងការពិនិត្យព្យាបាលសត្វ អនាម័យម្ហូបអាហារមានដើមកំណើតពីសត្វ និងវិធានការការពារ
- បណ្តុះបណ្តាលបច្ចេកទេសទាក់ទងនឹងសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាលដល់អ្នកពាក់ព័ន្ធ
- សហការជាមួយស្ថាប័ន អង្គការជាតិ និងអង្គការអន្តរជាតិលើការអង្កេត តាមដាន ស្រាវជ្រាវ ការចែករំលែកព័ត៌មានស្តីពីការបង្ការ ទប់ស្កាត់ និងចាត់វិធានការប្រយុទ្ធប្រឆាំងជំងឺសត្វ និងជំងឺស៊ូណូស
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រា៧ .-**

នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម មានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកា និងការងារទូទៅរបស់នាយកដ្ឋាន
- សិក្សា ស្រាវជ្រាវ រៀបចំបទដ្ឋានគតិយុត្ត និងបមាណីយនានាក្នុងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- សហការផ្សព្វផ្សាយបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- សហការវិភាគផ្សព្វផ្សាយព័ត៌មានទីផ្សារ តម្រូវការ ការផ្គត់ផ្គង់ និងតម្លៃសត្វ ផលិតផលសត្វ បសុឱសថ ចំណីសត្វ និងវត្ថុធាតុដើមសម្រាប់លាយផ្សំចំណីសត្វ
- តាមដាន វាយតម្លៃលើការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្ត ក្នុងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- តាមដាន ស្រាវជ្រាវ ធ្វើអធិការកិច្ច ចងក្រងសំណុំរឿងបញ្ជូនទៅតុលាការ និងដោះស្រាយបទល្មើសតាមនីតិវិធី
- ធ្វើអន្តរាគមន៍ និងចុះជួយទប់ស្កាត់បទល្មើសទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចនៅក្នុងការអនុវត្តច្បាប់ និងដោះស្រាយវិវាទ
- ចុះបញ្ជីបសុឱសថនិងចំណីសត្វ

- ចងក្រង រៀបចំបង្កើត តាមដាន ត្រួតពិនិត្យវាយតម្លៃសហគមន៍ចិញ្ចឹមសត្វ សហគមន៍ភ្នាក់ងារសុខភាពសត្វភូមិ សហគមន៍ និងអង្គការផ្សេងទៀតពាក់ព័ន្ធការងារផលិតកម្មនិងបសុព្យាបាល
- ស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រងទិន្នន័យឯកសារ ច្បាប់បទដ្ឋានគតិយុត្តនិងព័ត៌មានផ្សេងៗទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វសម្រាប់បម្រើការឱ្យការផ្សព្វផ្សាយនិងរក្សាទុកដាក់ឯកសារទាំងនេះ
- រៀបចំសៀវភៅ ឯកសារ អត្ថបទបច្ចេកទេស ទស្សនាវដ្តី និងព្រឹត្តិបត្រព័ត៌មានសម្រាប់ផ្សព្វផ្សាយ
- រៀបចំគេហទំព័រវិស័យសុខភាពសត្វនិងផលិតកម្មសត្វ និងផ្សព្វផ្សាយការងារវិស័យសុខភាពសត្វនិងផលិតកម្មសត្វដល់អ្នកពាក់ព័ន្ធតាមគ្រប់រូបភាព
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាននិងវាយតម្លៃការផ្សព្វផ្សាយទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ និងសហការអនុវត្តបង្ហាញ
- បណ្តុះបណ្តាល ចងក្រងឯកសារ និងវិធីសាស្ត្រផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រា៨ ..**

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកា និងការងារទូទៅរបស់វិទ្យាស្ថាន
- រៀបចំផែនការស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- អង្កេត តាមដាន ស្រាវជ្រាវជំងឺសត្វ និងស្រាវជ្រាវភាពស៊ាំរបស់មេរោគទៅនឹងបសុឱសថ
- សិក្សាពីការរាលដាលជំងឺសត្វ អេពីដេមីសាស្ត្រ និងវិភាគព័ត៌មានសុខភាពសត្វ
- ធ្វើរោគវិនិច្ឆ័យជំងឺសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវលើការងារចិញ្ចឹមសត្វ ការបង្កាត់ពូជសត្វ ចំណីសត្វនិងការផ្តល់ចំណីសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវសេនេទិចពូជសត្វ និងការបង្កាត់ពូជសត្វ នៅទីពិសោធន៍
- វិភាគ ពិសោធ ស្រាវជ្រាវគុណភាពចំណីសត្វ វត្ថុធាតុដើមផ្សំចំណីសត្វ សមាសធាតុផ្សំ និងសារធាតុបន្ថែមផ្សេងៗទៀតសម្រាប់ចំណីសត្វ
- វិភាគ ពិសោធ ស្រាវជ្រាវគុណភាពបសុឱសថ វិភាគរកកាកសំណល់បសុឱសថក្នុងផលិតផលសត្វ
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងវាយតម្លៃមន្ទីរពិសោធន៍វិភាគចំណីសត្វ
- បណ្តុះបណ្តាលលើការអង្កេតស្រាវជ្រាវជំងឺសត្វនិងការធ្វើរោគវិនិច្ឆ័យជំងឺសត្វ ការងារបច្ចេកទេសពិសោធវិភាគស្រាវជ្រាវលើការងារផលិតកម្មសត្វ
- រៀបចំឯកសារបណ្តុះបណ្តាល វិធីសាស្ត្រអង្កេតស្រាវជ្រាវ ការធ្វើរោគវិនិច្ឆ័យជំងឺសត្វ និងឯកសារទាក់ទងជំងឺសត្វ
- សហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ និងអង្គការអន្តរជាតិ លើការងារស្រាវជ្រាវសុខភាពសត្វ ការងារវិភាគជំងឺសត្វ និងការងារសិក្សាស្រាវជ្រាវផលិតកម្មសត្វ
- ផ្តល់សេវាកម្មបណ្តុះបណ្តាល ពិសោធ ស្រាវជ្រាវពូជសត្វ បង្កាត់ពូជ និងវិភាគចំណីសត្វ វត្ថុធាតុដើមផ្សំចំណីសត្វ សារធាតុផ្សំចំណីសត្វសារធាតុបន្ថែមសម្រាប់ផ្សំចំណីសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រា៩ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៧ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខ ៣៦២៣ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា និងបញ្ជូនមកៈ

-ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

" ដើម្បីជូនជ្រាប "

-ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត

" ដើម្បីជ្រាប និងមុខការ "

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦

**ត.ប រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គលេខាធិការ**